# បរិត្តកាសនាយាចនគាថា

## ពាក្យអារាធនាព្រះភិក្ខុសង្ឃសូមអោយចំរើនព្រះបរិត្ត

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វទុក្ខវិនាសាយ បរិត្តំព្រូថមង្គលំ។

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វភយវិនាសាយ បរិត្តំព្រូថមង្គលំ។

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វរោគវិនាសាយ បរិត្តំព្រូថមង្គលំ។

ប្រែថា:សូមព្រះករុណាទាំងឡាយ ចំរើននូវព្រះបរិត្តជាជ័យមង្គល ដើម្បីនឹងការពារ បញ្ចៀសនូវវិបត្តគឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងអោយសំរេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បី នឹងញុាំងទុក្ខ ភ័យ រោគ ទាំងអស់អោយវិនាសបាត់ទៅ។

លុះលោកអាចារ្យអារាធនាដូច្នេះហើយ លោកសង្ឃអ្នកចំរើនព្រះបរិត្តនោះ ត្រូវសូត្រធម៌ សគ្គេ កាមេ ។ល។ អយម្ភទន្តា ប្រកាសអញ្ជើញទេវតារួចហើយ ទើបចំរើន ព្រះបរិត្តជាពុទ្ធមន្តតាមគួរដល់ពុទ្ធានុញ្ញាត្តិក្នុងខុទ្ទកវត្ថុខន្ធកៈក្នុងព្រះវិន័យ។

# ទេវតាបកាសនគាថា

## ពាក្យប្រកាសអញ្ជើញពួកទេវតា

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ចគាមេ ត

រុនេគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វ

នាគា តិដ្ឋន្តា សន្តិកេ យំ មុ និវរចនំ សាធវោ មេ សុណន្តុ។ ធម្មស្សវនកាលោ

អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភទន្តា

ប្រែថា :ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភព និងរូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ រឺភ្នំដែលដែលដាច់ក្តី អែដំអាកាសក្តី នៅនាកោះ និងដែន និង

ស្រុកក្តី នៅនាដើមព្រឹក្ស និងព្រៃញាតស្បាត រឺទីស្រែចំការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកគោក រឺទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញប្រជុំគ្នា ក្នុងទីនេះ ពាក្យអែណាដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ ដែលយើង នឹងសូត្រអិលូវនេះ លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ដោយគោរព ។ ធម្មស្សវនកាលោ អយម្ភទន្តា បពិតលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះជាវេលាគួរនឹងស្តាប់នូវព្រះធម៌។

# ធម្មទេសនាយាចនគាថា

## ពាក្យសូត្រអារាធនាលោកអ្នកសំដែងធម៌

ព្រហ្មា ច លោកាធិបតី សហម្បតី កតញ្ជលី អន្ធិវរំ អាយា ចថសន្តឹថ សត្តាប្បរជក្ខ
ជាតិកា ទេសេតុ ធម្មំ អនុកម្បិមំ បជំ។ សទ្ធម្មភេរី វិនយញ្ញា កាយំ សុតញ្ញា ពន្ធំ អភិ
ធម្មចម្មំ អាកោដយន្តោ ចតុសច្ចទណ្ឌំ បញ្ញោធ នេយ្យេ បរិសាយ មជ្ឈេ។ អេវំ ស
ហម្បតីព្រហ្មា ភគវន្តំ អាយាចថ តុណ្ហីភាវេន តំ ពុទ្ធោ ការុញ្ញោនាធិវាសយ តម្ហារុដ្ឋា
យ បាទេនមិគទាយំ តតោ គតោបញ្ញវគ្យាទយោ នេយ្យេ អមំ បាយេសិ ធម្មតោ ត
តោ បភូតិសម្ពុទ្ធោ អន្ធនា ធម្មទេសនំមាយវស្សានិ ទសេសិ សត្តានំ អត្ថសិទ្ធកំ។តេន
សាធុអយ្យោភន្តេ ទេសេតុ ធម្មទេសនំ សញ្ញាយិធ បរិសាយអនុកម្បម្បិ កាតវេ។

គ្រានោះសហម្បតី ព្រហ្មជាអិស្សូរលោកា ចូរគាល់ព្រះសស្តា លើកហត្ថសិរោរាប។ ហើយពោលពាក្យទូលថា សូមករុណាស្តេចទ្រង់ជ្រាប ត្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់។ ទន្ទឹងព្រះធម៌ថៃ ជានិស្ស័យបច្ច័យច្បាស់ អីលូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ។ សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ស៍ណ៍ឡើយ អីលូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ។ បើបានស្តាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា។ ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោ យល់។ ត្រៃលោកគោកត្រៃលក្ស៍ណ៍ សង្សារចក្រវិលមិនដល់អវិជ្ជា ជាវិសគល់ ជាបច្ច័យនៃសង្ខារ។ នាំសត្វអោយសោកសៅ លិចលង់នៅក្នុងសង្សារ បញ្ចមារមោហន្ធ

ការរិតរុំហ៊ុមជុំជាប់នៅ។ ហេតុនោះសូមព្រះអង្គប្រោសស្រោចស្រង់ដាក់សំពៅ ចំលងសត្វឆ្លោះទៅ កាន់ត្រើយត្រាននិព្វាននាយ។ ដូចកលប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ បំភ្លឺសត្វទាំងឡាយ អោយសប្បាយក្សាន្តភិរម្យ។ ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស។ អរិយសច្ចជាអន្លូង សំរាប់ទូងអោយលឺច្បាស់ សត្វលោកងោកងុយណាស់ លឺស្គរដាស់ក្រោកឡើងបាន។ បរិស័ទ៨ចំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន ខ្លះផុសចាំសូរ្យឆាន រះនិងរីកដោយរស្មី។ ព្រះធម៌ជាសូសែង រះឡើងថែងចាំងរង្សី បំភ្លឺលោកទាំងបី អោយយល់ផ្លូវឋានសុខា។

សហម្បតីព្រហ្ម អោនបង្គំអារាធនា សំដេចព្រះភគវា ដោយគាថាយ៉ាងនេះអែង។ ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសំដែង ដោយតុណ្ហីភាពថ្លែង តាមភាវគុណករុណា។ ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា យាងចេញចរលីលា ពីទីនោះដោយព្រះបាទ។ ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីជាអាទិ អោយផឹកអម្រិតជាតិ រសនិព្វានជាធម្មតា។ ចាប់ដើមពីនោះអែង ទ្រង់សំដែងធម៌ទេសនា ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ។ ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ សំរេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ។

ហេតុនោះអិលូវនេះ យើងខ្ញុំនេះសាទរក្រៃ បពិតព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា។ អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា អោយកើតមានបញ្ញា ប្រាកដនាទីនេះហោង។